# មេរៀនទី ១៤៤: អេលីសេជួយស្ត្រីមេម៉ាយ និងកូនប្រុសរបស់នាង

## ២ ពង្សាវតារក្សត្រ ៤:១-៧

**គោលបំណង៖** ព្រះខ្វល់ខ្វាយចំពោះមនុស្សដែលមានសេចក្ដីត្រូវការ។

**ខគម្ពីរចងចាំ៖ អេសាយ ៤១:១៣** *"ដ្បិតអញនេះគឺយេហូវ៉ាជាព្រះនៃឯង អញនឹងកាន់ដៃស្តាំឯង ដោយពោលនឹងឯងថា កុំឲ្យភ័យខ្លាចឡើយ អញនឹងជួយឯង។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖(សូមអានហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**

ព្រះយេស៊ូវបានបង្ហាញពួកយើងពីសេចក្ដីជំនឿដ៏រស់ពិតប្រាកដដែលមាននៅក្នុងយើង ថាមានលក្ខណៈយ៉ាងដូចម្ដេច។ ព្រះយេស៊ូវ និងព្រះគឺតែមួយ ហើយព្រះយេស៊ូវគឺដឹងប្រាកដថាទ្រង់អាចពឹងលើព្រះបានគ្រប់ពេល។ ហើយតាមរយៈការដែលយើងមានទំនាក់ទំនងជាមួយទ្រង់ យើងក៏អាចរស់នៅក្នុងសេចក្ដីជំនឿបានដែរ។ ការដែលមានសេចក្ដីត្រូវការអាចនាំយើងឲ្យពឹងផ្អែកទៅលើព្រះបានកាន់តែខ្លាំង។ ក្នុងនាមជាគ្រូបង្រៀនអ្នកត្រូវតែពឹងផ្អែកទៅលើព្រះឲ្យជួយអ្នកក្នុងការបង្រៀនផងដែរ។ តើកន្លងមកព្រះបានជួយអ្នកក្នុងការបង្រៀនដូចម្ដេចខ្លះ? សូមទូលសុំព្រះឲ្យជួយ និងពឹងផ្អែកលើព្រះអង្គ។ ព្រះគឺរង់ចាំក្នុងការបង្ហាញអ្នកពីរបៀប ដែលទ្រង់យកចិត្តទុកដាក់ពីសេចក្ដីត្រូវការរបស់អ្នក។

**ចំរៀង៖** ១.ព្រះយើងជាព្រះអស្ចារ្យ ២.ព្រះអម្ចាស់យើងល្អណាស់ ៣.ទ្រង់មិនដែលខាន

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ៣. ល្បែងកំសាន្ត «ហុចតគ្នា»

**សម្ភារៈដែលត្រូវការ៖** បាល់ ឧបករណ៍ចាក់ភ្លេង (ត្រៀមរង្វាន់សម្រាប់កុមារគ្រប់ៗគ្នា)

១. ឲ្យកុមារគ្រប់គ្នាអង្គុយនៅលើកៅអីជារង្វង់ហើយបែរមុខចេញក្រៅ។

២. ឲ្យបាល់ទៅកុមារណាម្នាក់ នៅពេលដែលគ្រូចាក់ភ្លេងកុមារត្រូវបញ្ជូនបាល់ទៅកុមារបន្តបន្ទាប់គ្នា។

៣. ប្រសិនបើកុមារណាម្នាក់កាន់បាល់នៅពេលភ្លេងឈប់ កុមារនោះនឹងទទួលបានរង្វាន់ ហើយឈប់លេងល្បែងនេះ។

៤. បន្តលេងល្បែងនេះរហូតដល់កុមារទទួលបានរង្វាន់គ្រប់ៗគ្នា។

៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា កុមារគ្រប់ៗគ្នាសុទ្ធតែមានឱកាសទទួលបានបាល់ ហើយព្រះគឺយកចិត្តទុកដាក់ចំពោះយើងគ្រប់ៗគ្នា។



### ៤. ការណែនាំមេរៀន

រឿងមួយដែលមនុស្សទូទៅគ្រប់គ្នាមាននោះគឺសេចក្ដីត្រូវការ។ ពួកយើងត្រូវការអាហារ ទឹក ផ្ទះ និងមនុស្សដែលបារម្ភពីយើង។ ដំណឹងល្អគឺថា ព្រះគឺយកចិត្តទុកដាក់ចំពោះមនុស្សដែលត្រូវការ! ថ្ងៃនេះយើងនឹងរៀនអំពីរបៀបដែលព្រះយកចិត្តទុកដាក់ចំពោះស្ត្រីមេម៉ាយ និងកូនប្រុសទាំងពីររបស់នាង នៅពេលដែលពួកគេមានតម្រូវការ!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

អេលីសេគឺជាហោរាដែលទទួលបានអំណាចរបស់អេលីយ៉ាទ្វេដង នៅពេលដែលព្រះបានលើកអេលីយ៉ាទៅឯនគរស្ថានសួគ៌ដោយរថជាភ្លើង។ គាត់បានបម្រើនៅឯភាគខាងជើងនៃរាជាណាចក្រអ៊ីស្រាអែល។ ថ្ងៃមួយមានស្ត្រីមេម៉ាយក្រីក្រម្នាក់ ដែលប្ដីរបស់គាត់ធ្លាប់ធ្វើជាហោរា ហើយបានស្លាប់បានមកឯអេលីសេ។ ប៉ុន្តែមុនពេលប្ដីរបស់គាត់ស្លាប់បានបន្សល់ទុកនូវបំណុលជាច្រើន ដែលគាត់មិនអាចសងគេអស់។ គាត់គឺមានកូនប្រុសពីរនាក់ដែលម្ចាស់បំណុលបំរុងនឹងយកទៅធ្វើជាទាសករ រហូតដល់ពួកគេអាចសងបំណុលអស់!

នៅពេលដែលអេលីសេសួរនាងថា តើនាងមានអ្វីនៅក្នុងផ្ទះខ្លះ គាត់មានតែដបប្រេង១ប៉ុណ្ណោះ គាត់គឺពិតជាក្រីក្រខ្លាំងណាស់។ មនុស្សគឺប្រើប្រេងសម្រាប់ធ្វើអាហារ ប៉ុន្តែពួកគេក៏ប្រើសម្រាប់ស្បែក ចង្កៀង និងធ្វើថ្នាំផងដែរ។ ដោយព្រោះតែគ្រប់គ្នាត្រូវការប្រេងនោះ ពេលខ្លះគេប្រើវាដូចជាលុយអីចឹង។ អេលីសេបានប្រាប់ទៅស្ត្រីមេម៉ាយនោះឲ្យប្រើកូនរបស់នាងទៅខ្ចីដបប្រេងទទេពីអ្នកជិតខាង។ ហើយគាត់បានប្រាប់ឲ្យខ្ចីឲ្យបានច្រើនតាមដែលអាចធ្វើបាន។

នៅពេលដែលពួកគេបានយកដបទាំងអស់មកហើយ អេលីសេបានប្រាប់ឲ្យស្ត្រីមេម៉ាយចាប់ផ្ដើមចាក់ប្រេងបន្តិចដែលនាងមានចូលទៅក្នុងដបទាំងអស់ដែលកូនគាត់បានយកមកផ្ទះនោះ។ នេះគឺមិនសមហេតុផលទេសម្រាប់នាង ពីព្រោះថាតើគាត់អាចចាក់ប្រេងតែបន្តិច ដែលគាត់មានឲ្យពេញដបដ៏ធំនោះបានយ៉ាងដូចម្ដេច? ប៉ុន្តែនាងបានស្ដាប់បង្គាប់ ព្រោះនាងបានដឹងថាអេលីសេគឺជាហោរារបស់ព្រះ។ ជាការអស្ចារ្យគាត់អាចចាក់ប្រេងបំពេញដបទាំងអស់តាមរយៈប្រេងនៅក្នុងដបបន្តិចបន្តួចប៉ុណ្ណោះ! បន្ទាប់មកអេលីសេបានប្រាប់ឲ្យស្ត្រីមេម៉ាយលក់ប្រេងដែលគាត់មាននោះ រួចសងបំណុលគេវិញ ហើយឲ្យពួកគេបន្តរស់នៅជាមួយប្រាក់ដែលនៅសេសសល់។

ស្ត្រីមេម៉ាយនិងកូនប្រុសទាំងពីររបស់គាត់ធ្លាប់គិតថា ស្ថានភាពរបស់ពួកគេគឺពិបាកខ្លាំងណាស់ និងមិនមានសង្ឃឹមទាល់តែសោះ។ ប៉ុន្តែព្រះបានប្រើអេលីសេមក នៅពេលដែលពួកគេមានសេចក្ដីត្រូវការខ្លាំងបំផុត។ ព្រះស្រលាញ់មនុស្សគ្រប់គ្នា និងគ្រប់ទីកន្លែងទាំងអស់។ ប៉ុន្តែព្រះគឺយកចិត្តទុកដាក់ជាពិសេសសម្រាប់អ្នកដែលខ្វះខាត។ មនុស្សមួយចំនួនមានការស្រេកឃ្លាន។ ព្រះស្រលាញ់អស់អ្នកដែលស្រេកឃ្លាន។ មនុស្សមួយចំនួនមិនមានផ្ទះសម្បែងក្នុងការស្នាក់នៅ ហើយមិនមានក្រុមគ្រួសារដែលស្រលាញ់ពួកគេ។ ព្រះស្រលាញ់អស់អ្នកដែលគ្មានផ្ទះ និងគ្មានក្រុមគ្រួសារ។ ហើយព្រះគឺស្រលាញ់ដល់អ្នកដែលមានសេចក្ដីត្រូវការគ្រប់ៗគ្នា។

សូមក្រឡេកមើលទៅមនុស្សដែលនៅជុំវិញអ្នក ហើយមើលពីអ្វីដែលពួកគេត្រូវការ។ ប្រហែលជាព្រះអាចប្រើអ្នកដូចជាព្រះបានប្រើអេលីសេក្នុងការជួយពួកគេផងដែរ។ អ្នកអាចជួយដល់អ្នកដែលមានសេចក្ដីត្រូវការនោះ តាមរយៈការចំណាយពេលវេលារបស់អ្នកជាមួយពួកគេ ឬតាមរយៈការនិយាយពាក្យដែលបញ្ជាក់ថាអ្នកបារម្ភពីពួកគេ ឬក៏អ្នកអាចចែករំលែកនូវអ្វីដែលអ្នកមាន ដែលពួកគេកំពុងត្រូវការផងដែរ។ សូមចាំថាព្រះយេស៊ូវគឺស្រលាញ់ និងខ្វាយខ្វល់អស់អ្នកដែលមានសេចក្ដីត្រូវការ!

## ៦. សំនួរពិភាក្សា

១. តើអ្នកបានដឹងអ្វីខ្លះអំពីអេលីសេ?

*គាត់បានបម្រើនៅឯភាគខាងជើងនៃរាជាណាចក្រអ៊ីស្រាអែល គាត់ទទួលបានអំណាចរបស់អេលីយ៉ាទ្វេដង នៅពេលដែលព្រះបានលើកអេលីយ៉ាទៅឯនគរស្ថានសួគ៌ដោយរថជាភ្លើង*

២. តើស្ត្រីមេម៉ាយមានបញ្ហាអ្វីបន្ទាប់ពីប្ដីរបស់គាត់ស្លាប់ទៅ?

*គាត់មិនអាចសងបំណុលអស់ ហើយកូនប្រុសទាំងពីររបស់គាត់ជិតត្រូវគេចាប់យកទៅធ្វើជាទេសករ*

៣. តើលោកអេលីសេបានប្រាប់ឲ្យស្ត្រីមេម៉ាយនិងកូនប្រុសទាំងពីររបស់គាត់ធ្វើអ្វី?

*ឲ្យទៅស្វែងរកដបទទេមកឲ្យបានច្រើន*

៤. តើមានរឿងអ្វីកើតឡើងនៅពេលដែលស្ត្រីមេម៉ាយនោះបានចាក់ប្រេងបន្តិចដែលគាត់មានចូលទៅក្នុងដបធំទទេនោះ? *គឺវាបានពេញគ្រប់ដប*

៥. តើការនេះអាចកើតឡើងបានយ៉ាងដូចម្ដេច? *វាអាចកើតឡើងបានដោយសារតែព្រះដែលពេញដោយព្រះចេស្ដា ហើយទ្រង់ខ្វាយខ្វល់ពីមនុស្សដែលមានសេចក្ដីត្រូវការ*

៦. សូមគិតពីបុគ្គលដែលមានសេចក្ដីត្រូវការនៅជុំវិញអ្នក។ តើអ្នកអាចជួយគេបានដោយរបៀបណា?

*ទុកឲ្យកុមារជាអ្នកឆ្លើយ*

## ៧. ល្បែងកំសាន្ត «ផ្លុំម្សៅ»

**សម្ភារៈដែលត្រូវការ៖** ម្សៅ តុ និងចាន



១. ចែកកុមារជា ២ក្រុម ហើយឲ្យពួកគេឈរជាជួរចម្ងាយ ៥ម៉ែត្រពីតុ។

២. ដាក់ម្សៅក្នុងចាន ហើយដាក់វានៅលើតុ។

៣. នៅពេលដែលគ្រូរាប់ ១ ២ ៣ កុមារទី១ ពីក្រុមទាំង២ ត្រូវរត់ទៅកាន់តុហើយផ្លុំម្សៅនៅក្នុងចាននោះម្ដងរួចរត់ត្រឡប់មកក្រោយវិញ។

៤. កុមារបន្ទាប់ត្រូវរត់បន្តទៅកាន់តុ និងផ្លុំម្សៅម្ដងទៀត។ បន្តលេងល្បែងនេះរហូតដល់កុមារគ្រប់ៗគ្នាបានផ្លុំម្សៅនោះគ្រប់ៗគ្នា។

៥. ក្រុមណាដែលអាចផ្លុំម្សៅអស់ពីចានបានមុនគេក្រុមនោះជាអ្នកឈ្នះ។

៦. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា វាគឺមិនអាចទៅរួចនោះទេ ដែលកុមារអាចផ្លុំម្សៅអស់ពីចាននោះ។ ក៏ដូចគ្នានេះដែរ វាគឺគ្មានអ្វីដែលអាចបញ្ឈប់ព្រះ មិនឲ្យយកចិត្តទុកដាក់ចិត្តចំពោះអ្នកបានឡើយ។ ព្រះគឺតែងតែយកចិត្តទុកដាក់អស់អ្នកដែលមានសេចក្ដីត្រូវការ។

## ៨. ខគម្ពីរចងចាំ អេសាយ ៤១:១៣

## ៩. ហត្ថកម្ម ផាត់ពណ៌ “អេលីសេជួយស្ត្រីមេម៉ាយ និងកូនប្រុសទាំងពីររបស់នាង”

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

# អេលីសេជួយស្ត្រីមេម៉ាយ និងកូនប្រុសទាំងពីររបស់នាង



**សូមសរសេរខគម្ពីរចងចាំ:** ______________________________

______________________________________________

______________________________________________

______________________________________________

______________________________________________